# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

១៨-១០-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១០០៦/៤១៩ ស្ដីពីការតែងតាំង អគ្គសវនករ ០១ រូប និង អគ្គសវនកររង ០២ រូប នៃអាជ្ញាធរសវនកម្មជាតិ អាណត្តិទី ២ ៧០៣៥

២០-១០-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១០០៦/៤២០ ស្ដីពីការផ្ទេរក្របខ័ណ្ឌលោក **អ៊ុក តុបបុត្រា** និងលោក **គិន គា** បច្ចុប្បន្នអនុមន្ត្រី ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ទៅជាអនុមន្ត្រី ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌគ្រប់គ្រងរដ្ឋបាលនៅទីស្ដីការ គណៈរដ្ឋមន្ត្រី ៧០៣៦

២១-១០-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១០០៦/៤២៣ ស្ដីពីការបំពាក់គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និង កីឡា ចំនួន ១២ រូប ដែលមានគុណបំណាច់ខ្ពស់ក្នុងការបំរើជាតិមាតុភូមិ ៧០៣៧

២១-១០-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១០០៦/៤២៦ ស្ដីពីការតែងតាំងឯកឧត្តម **ហេង ណារ៉េត** ជាទីប្រឹក្សាក្រសួងបរិស្ថាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៧០៣៩

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

២០-១០-២០០៦ -អនុក្រឹត្យលេខ ១០៧ អនក្រ.បក ស្ដីពីការបង្កើតក្រុមការងារសម្រាប់អនុវត្តគម្រោងស្តារ ជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយគម្រោងថវិកាកម្ចីធនាគារអភិវឌ្ឍន៍អាស៊ី ៧០៤០

២០-១០-២០០៦ -អនុក្រឹត្យលេខ ១០៨ អនក្រ.បក ស្ដីពីការធ្វើអនុបយោគដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ របស់រដ្ឋ និងការផ្ដល់សម្បទានដីសង្គមកិច្ច ជូនប្រជាពលរដ្ឋចំនួន ៤១ គ្រួសារ នៅភូមិ តាគ្រក់ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ៧០៤៥

២៣-១០-២០០៦ -អនុក្រឹត្យលេខ ១០៩ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ ៧០៤៧

២៣-១០-២០០៦ -អនុក្រឹត្យលេខ ១១០ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៧០៦១

២៣-១០-២០០៦ -អនុក្រឹត្យលេខ ៦៨៨ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧០៦៣

២៣-១០-២០០៦ -អនុក្រឹត្យលេខ ៦៨៩ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៧០៦៤

២៣-១០-២០០៦ -អនុក្រឹត្យលេខ ៦៩០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧០៦៦

## ២-បទបញ្ជា

២៣-១០-២០០៦ -បទបញ្ជាលេខ ០៣ បប ស្តីពីការពង្រឹងសន្តិសុខ និងសុវត្ថិភាពនៅតាមអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ៧០៦៧

## III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១១-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) មេឌីស៊ីន ស៊ីបផ្លាយ អេន មេនូហ្វេកឈ័រ** ៧០៧១

១២-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថុង ហេង ហ្វើនីឡាយហ្វ៊ី** ៧០៧៣

១២-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ អិល ៩៩** ៧០៧៥

១២-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ.អេស. ផេស៊ីហ្វិក គ្រុប អិលធីឌី** ៧០៧៧

១២-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ែត អន ខូ អិលធីឌី** ៧០៧៩

១២-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៦៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រិក្ស អ៊ិនធើណេសិនណាល អិលធីឌី** ៧០៨១

១៣-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វិឌ្ឍា អភិវឌ្ឍន៍ គ្រុប** ៧០៨៣

# ព្រះរាជក្រឹត្យ

នស/រកត/១០០៦/៤១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/0៧0៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២00៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ 0២/នស/៩៤ ចុះថ្ងៃទី ២0 ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/0៣00/១0 ចុះថ្ងៃទី 0៣ ខែ មីនា ឆ្នាំ ២000 ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/0៨0៦/0២៤ ចុះថ្ងៃទី ៣0 ខែ សីហា ឆ្នាំ ២00៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨ នៃច្បាប់ ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតទុកចិត្តរបស់រដ្ឋសភាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ថ្ងៃទី១៦ ខែតុលា ឆ្នាំ ២00៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំង អគ្គសវនករ 0១រូប និងអគ្គសវនកររង 0២រូប នៃអាជ្ញាធរសវនកម្មជាតិ អាណត្តិទី២ ដែលមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **អ៊ុត ឈន** ជាអគ្គសវនករ
២-ឯកឧត្តម **ឆាយ គីម** ជាអគ្គសវនកររង
៣-ឯកឧត្តម **សេង រ៉ុន** ជាអគ្គសវនកររង

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។/.

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២00៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣រ៤.០៦១០. ៤៤៣ លេខ: ៧៩៧ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២00៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៦/៤២០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្ននខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្ទេរក្របខ័ណ្ឌលោក **អ៊ុក គុបបុត្រា** និងលោក **គិន ភា** បច្ចុប្បន្នអនុមន្ត្រី ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ទៅជាអនុមន្ត្រី ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្ត អោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧.០៦១០.៤៤៤

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០០៦*

ប្រ.ក.៣៩៨ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៦
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល
ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៦/៤២៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** បំពាក់ គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ចំនួន ១២រូប ដែលមានគុណបំណាច់ខ្ពស់ក្នុងការបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១-ឯកឧត្តម **កុល ផេង**

២-ឯកឧត្តម **អ៊ឹម សិទ្ធី**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

១-ឯកឧត្តម **ម៉ក់ វ៉ាន់**

២-ឯកឧត្តម **ម៉ិន សុខ**

៣-ឯកឧត្តម **ពិត ចំណាន**

៤-ឯកឧត្តម **ម៉ូ ជុំសេរី**

៥-ឯកឧត្តម **ជ័យ ចាប**

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

១-ឯកឧត្តម **ណាត ប៊ុនរឿន**

២-ឯកឧត្តម **បួយ ប៊ុណ្ណា**

R.W

៣-ឯកឧត្តម ជា សែ

៤-ឯកឧត្តម លី សុមុនី

៥-ឯកឧត្តម ចារក់ សឹងលី

**មាត្រា២ៈ** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ៈ** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*៣៧៧.០៦១០.៤៤៧*

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ,ថ្ងៃទី ៤១ ខែ តុលា ឆ្នាំ ២០០៦*

លេខ : ៤០០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ១៧ ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១០០៦/៤២៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **ហេង ណារ៉េត** ជាទីប្រឹក្សាក្រសួងបរិស្ថាន មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.០៦១០.៤៥០

ធ្វើនៅព្រះបរមរាជវាំង.រាជធានីភ្នំពេញ. ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៦ លេខ :៣៩៩ ច.ល

**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ.ថ្ងៃទី២៣ ខែ១០ ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមការងារសម្រាប់អនុវត្តគម្រោងស្តារជួសជុល ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយគម្រោងឥណទានពីធនាគារអភិវឌ្ឍន៍អាស៊ី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតរាជាយស្ម័យយានកម្ពុជា ជាសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៧២ អនក្រ.តត ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគម្រោងផ្លូវដែកសិង្ហបូរី-គុនមិញ
- យោងតាមអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ស្តីពីគម្រោងស្តារជួសជុលឡើងវិញផ្លូវដែកនៅកម្ពុជា ដែលបានចុះហត្ថលេខានៅថ្ងៃទី[illegible] ឆ្នាំ២០០៦

# ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតក្រុមការងារសម្រាប់អនុវត្តគម្រោងកំណែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងរាជាយស្ម័យយានកម្ពុជា និង គម្រោងស្តារជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក ដោយឥណទានថវិកាកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

## ជំពូកទី ២
## សមាសភាព

**មាត្រា ២.-**

គណៈកម្មាធិការតម្រង់ទិស ត្រូវបានយកពីសមាសភាព ក្នុងមាត្រា ២ ជំពូកទី ១ នៃអនុក្រឹត្យលេខ ២៧២ អនក្រ.តត ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគម្រោងផ្លូវដែកសិង្ហបុរី គុនមិញ ។

**មាត្រា ៣.-**

ក្រុមប្រឹក្សាគ្រប់គ្រងសម្បទាន ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ុក ចាន់** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- ឯកឧត្តម **សុខុម ភគវន្តមុនី** | ប្រធានអគ្គនាយក រាជាយស្ម័យយានកម្ពុជា | អនុប្រធាន |
| ៣- ឯកឧត្តម **ស៊ុយ សាន** | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៤- តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| ៥- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៦- លោក **រិត បឿន** | នាយកអាជីវកម្ម និងដឹកជញ្ជូនសមាជិក រាជាយស្ម័យយានកម្ពុជា | សមាជិក |
| ៧- លោក **ហ៊ុយ រិទ្ធ** | នាយកក្បាលម៉ាស៊ីន និងទូរថភ្លើង រាជាយស្ម័យយានកម្ពុជា | សមាជិក |
| ៨- លោក **សុខ ណារី** | នាយករងអាជីវកម្ម និងដឹកជញ្ជូន រាជាយស្ម័យយានកម្ពុជា | សមាជិក |
| ៩- លោក **ញ៉ឹក ធីរវុឌ្ឍន៍** | នាយករងរដ្ឋបាល រាជាយស្ម័យយានកម្ពុជា | សមាជិក |

មាត្រា ៤.-

ក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តគម្រោងស្តារជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជាដែលមានសមាសភា
ដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោក ឃិត ប៊ុណ្ណា | នាយកមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស | នាយកគម្រោង |
| ២- លោក លី ប៊ូរិន | នាយកផ្លូវ ស្ពាន អាគារ<br>រាជាយស្វ័យយានកម្ពុជា | ប្រធានគ្រប់គ្រងបច្ចេកទេស |
| ៣- លោក ចាន់ សំឡេង | នាយករងផ្លូវ ស្ពាន អាគារ<br>រាជាយស្វ័យយានកម្ពុជា | ប្រធានគ្រប់គ្រងទូទៅ |
| ៤- លោក ឡៃ ប៊ុនតឹក | ប្រធានបណ្តាញផ្លូវដែកពាយ័ព្យទិស<br>រាជាយស្វ័យយានកម្ពុជា | ទទួលបន្ទុកបណ្តាញផ្លូវដែក<br>(ភ្នំពេញ ប៉ោយប៉ែត) |
| ៥- លោក ម៉េង លី | ប្រធានបណ្តាញសិល្បៈការ្យ និងការងារថ្មី<br>រាជាយស្វ័យយានកម្ពុជា | ទទួលបន្ទុកបណ្តាញផ្លូវដែក<br>(ភ្នំពេញ ក្រុងព្រះសីហនុ) |
| ៦- លោក អ៊ិត ស៊ានសុដល | មន្ត្រីនៃមជ្ឈមណ្ឌលស្រាវជ្រាវ<br>ក្រសួងសាធារណការ និងដឹកជញ្ជូន | ទទួលបន្ទុកលទ្ធកម្ម គណនេយ្យ |
| ៧- លោក នឹម ម៉ារីណា | មន្ត្រីនៃមជ្ឈមណ្ឌលស្រាវជ្រាវ<br>ក្រសួងសាធារណការ និងដឹកជញ្ជូន | ទទួលបន្ទុករដ្ឋបាល |
| ៨- លោក វេតន៍ សាម៉ន | មន្ត្រីខុទ្ទកាល័យ<br>ក្រសួងសាធារណការ និងដឹកជញ្ជូន | ជំនួយការរដ្ឋបាល |

មាត្រា ៥.-

ក្រុមការងារសម្រាប់អភិវឌ្ឍន៍ដីធ្លី ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- លោក ស៊ូ ផល្លី | នាយករងរដ្ឋបាល រាជាយស្វ័យយានកម្ពុជា | ប្រធាន |
| ២- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| ៣- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | | សមាជិក |
| ៤- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | |
| ៥- តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | | |
| ៦- លោក នៅ ឌីណា | រាជាយស្វ័យយានកម្ពុជា | |

## ជំពូកទី ៣
## តួនាទី និងភារកិច្ច

**មាត្រា ៦.-**

គណៈកម្មាធិការតម្រង់ទិស មានភារកិច្ចពិនិត្យ សម្របសម្រួល ផ្តល់អនុសាសន៍ និងធ្វើសេចក្តីសម្រេច លើការងារអនុវត្តគម្រោង។

**មាត្រា ៧.-**

អង្គភាពគ្រប់គ្រងសម្បទាន មានភារកិច្ចរៀបចំ ពិនិត្យ និងវាយតម្លៃលើឯកសារលទ្ធកម្ម ដើម្បីផ្តល់ សេចក្តីអនុសាសន៍ទៅប្រតិបត្តិករ ដែលជាក្រុមហ៊ុនឯកជនធ្វើអាជីវកម្មតាមផ្លូវដែកកម្ពុជា និងធ្វើការតាមដានត្រួតពិនិត្យ ផ្តល់ យោបល់លើការអនុវត្តកិច្ចសន្យាសម្បទានដល់ប្រតិបត្តិករ ដើម្បីរាយការណ៍ និងដាក់ជូនគណៈកម្មាធិការតម្រង់ទិស ដើម្បីពិនិត្យ និងសម្រេច។

**មាត្រា ៨.-**

ក្រុមការងារសម្រាប់អនុវត្តគម្រោង ទទួលខុសត្រូវលើការអនុវត្ត និងគ្រប់គ្រងគម្រោងស្តារជួសជុល សាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក រាប់បញ្ចូលទាំងលទ្ធកម្មសាងសង់ និងការដកប្រាក់កម្ចី។

**មាត្រា ៩.-**

ក្រុមការងារសម្រាប់អភិវឌ្ឍន៍ដីធ្លី មានភារកិច្ចធ្វើការអភិវឌ្ឍដីធ្លីជាអចលនទ្រព្យរបស់រាជាយស្ម័យយាន កម្ពុជា ហើយស្ថិតក្រោមការគ្រប់គ្រងរបស់សហគ្រាសសាធារណៈ រាជាយស្ម័យយានកម្ពុជា។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ១០.-**

គណៈកម្មាធិការតម្រង់ទិស ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការទំនាក់ទំនងការងាររបស់ខ្លួន។

**មាត្រា ១១.-**

អង្គភាពគ្រប់គ្រងសម្បទាន និងក្រុមការងារបច្ចេកទេសអនុវត្តគម្រោង ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងការទំនាក់ទំនងការងាររបស់ខ្លួន។

**មាត្រា ១២.-**

ក្រុមការងារសម្រាប់អភិវឌ្ឍន៍ដីធ្លី ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់រាជាយស្វ័យយានកម្ពុជា។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ តុលា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**......១០៧......អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការធ្វើអនុបយោគដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងការផ្តល់សម្បទានដីសង្គមកិច្ច ជូនប្រជាពលរដ្ឋចំនួន ៤១ គ្រួសារ នៅភូមិតាគ្រក់ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស /រកម /០៦៩៩ /០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦ /០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- យោងលិខិតរបស់រដ្ឋបាលព្រៃឈើលេខ ១២៥០ រព. ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៦ ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដី នៃដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ទំហំ ៥ ហិកតា ១.២៩៥ ម$^{២}$ ( ប្រាំហិកតា មួយពាន់ពីររយកៅសិបប្រាំបួនម៉ែត្រការ៉េ) ស្ថិតនៅភូមិតាគ្រក់ ឃុំគ្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឱ្យប្រែក្លាយទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។ ផែនទីបញ្ជាក់ទីតាំងត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគខាងលើនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងបែងចែករបស់គណៈកម្មាធិការប្រើប្រាស់ និង បែងចែកដីខេត្តបាត់ដំបង ស្របតាមច្បាប់ជាធរមាន។

**មាត្រា ៣.-**

ត្រូវបានផ្តល់ជាសម្បទានដីសង្គមកិច្ច ជូនប្រជាពលរដ្ឋចំនួន ៤១ គ្រួសារដូចមានបញ្ជីឈ្មោះក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ នូវផ្ទៃដីអនុបយោគ នៃដែនដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ដូចបានកំណត់ទំហំ និងទីតាំងដី ក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ /.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ខែ តុលា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ
## របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៦

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ កំណត់ការរៀបចំ បេសកកម្ម សមាសភាព រចនាសម្ព័ន្ធ និងមុខការនៃបណ្តាអង្គភាពនានារបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលសរសេរអក្សរកាត់ថា (អ.ជ.ប.ជ.អ.) ។

## ជំពូកទី ២

## បេសកកម្ម សមាសភាព រចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ អ.ជ.ប.ជ.អ.

មាត្រា ២.-

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាស្ថាប័នជាតិមានលក្ខណៈជាពហុវិស័យ ដែលមានបេសកកម្មដឹកនាំ និង អនុវត្តការងារ បង្ការ និងការប្រយុទ្ធទប់ស្កាត់ ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ។

មាត្រា ៣.-

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១- នាយករដ្ឋមន្ត្រី ឬសមាជិករាជរដ្ឋាភិបាល ០១ រូប | | ប្រធាន |
| ២- ឥស្សរជនជាន់ខ្ពស់ | ០១ រូប ឬ ច្រើនរូប | អនុប្រធាន |
| ៣- រដ្ឋលេខាធិការ | ទីស្តីការគណៈរដ្ឋមន្ត្រី ០១ រូប | សមាជិក |
| ៤- រដ្ឋលេខាធិការ | ០១ រូប នៃក្រសួងនានា | សមាជិក |
| ៥- អនុរដ្ឋលេខាធិការ | ០១រូប នៃរដ្ឋលេខាធិការដ្ឋាន | សមាជិក |
| ៦- អនុប្រធានទី១ សមាគមជាតិកាកបាទក្រហមកម្ពុជា | | សមាជិក |
| ៧- អភិបាលរងរាជធានីភ្នំពេញ ០១រូប | | សមាជិក |
| ៨- អភិបាល ឬអភិបាលរងខេត្ត ក្រុង ០១ រូបគ្រប់ខេត្ត ក្រុង | | សមាជិក |

សមាសភាពនៃ **អ.ជ.ប.ជ.អ.** ត្រូវកំណត់ដោយ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

មាត្រា ៤.-

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមុខងារ និងភារកិច្ច ដូចតទៅ ៖

- លើកគោលនយោបាយជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច
- លើកផែនការយុទ្ធសាស្ត្រ សម្រាប់អនុវត្តគោលនយោបាយជាតិជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច
- លើកយោបល់ជូនរាជរដ្ឋាភិបាល អំពីបញ្ហាទាំងឡាយណា ដែលទាក់ទងនឹងស្ថានភាពជំងឺអេដស៍
- សម្របសម្រួល និងដឹកនាំអនុវត្តច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- សម្របសម្រួល ណែនាំ និងបង្កលក្ខណៈ អនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ នៅតាមក្រសួង ស្ថាប័ន ពាក់ព័ន្ធនានា អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឯកជន ឱ្យមាននិរន្តរភាព
- ផ្សព្វផ្សាយច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- ស្វែងរកជំនួយពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដើម្បីគាំទ្រការអនុវត្តផែនការជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ផ្លាស់ប្តូរបច្ចេកទេស និងបទពិសោធន៍ជាមួយប្រទេសទាំងឡាយ ដែលមានបញ្ហាអេដស៍
- ទ្រទ្រង់ សម្របសម្រួល និងសហការធ្វើការងារស្រាវជ្រាវអេពីដេមីសាស្ត្រ និងស្រាវជ្រាវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គម
- ផ្តល់យោបល់ ណែនាំស្តីពីវិធានការ ដែលមានចែងក្នុងច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ដល់មន្ទីរពិសោធន៍ មន្ទីរពេទ្យនិងកន្លែងថែទាំព្យាបាលអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍
- ពិនិត្យអនុម័តលើគម្រោងកម្មវិធីអប់រំ ដែលត្រូវធ្វើការផ្សព្វផ្សាយនៅតាម ក្រសួង ស្ថាប័ន សាលារៀន តាមវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី និងលើកម្មវិធីអប់រំដោយផ្ទាល់
- ទទួលខុសត្រូវរៀបចំច្បាប់ និងចេញលិខិតបទដ្ឋានទាំងឡាយ ស្តីពីការត្រួតពិនិត្យ និងការអនុវត្តបទប្បញ្ញត្តិផ្សេងៗ ដែលទាក់ទងនឹងជំងឺអេដស៍ ដោយសង្កត់ធ្ងន់លើវិស័យសិទ្ធិមនុស្ស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

មាត្រា ៥.-

ប្រធាន អ.ជ.ប.ជ.អ. មានភារកិច្ចដូចតទៅ ៖

- សម្របសម្រួលជាពហុវិស័យ ដើម្បីឱ្យសមស្របនឹងការវិវត្តនៃការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍
- ដឹកនាំគ្រប់គ្រងនិងចាត់ចែងការងារទូទៅ នៃ អ.ជ.ប.ជ.អ.

- ដឹកនាំកិច្ចប្រជុំពិភាក្សាពេញអង្គនៃ អ.ជ.ម.ជ.អ. ។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំពិភាក្សា នេះជំនួស
- ស្នើ និងដំឡើងថ្នាក់ ឬឋានន្តរសក្តិដល់បុគ្គលិកនៃ អ.ជ.ម.ជ.អ. និងដាក់វិន័យទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ អ.ជ.ម.ជ.អ. និងច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា សំដៅលើកកម្ពស់ប្រសិទ្ធភាព សមត្ថភាព និងការស្មោគស្ម័ គ្រក្នុងការធ្វើការងារឱ្យបានកម្រិតខ្ពស់
- ធ្វើរបាយការណ៍បូកសរុប រាល់សកម្មភាពការងាររបស់ អ.ជ.ម.ជ.អ. ជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានទីប្រឹក្សាមួយចំនួន ដើម្បីជួយការងារ ។

អនុប្រធាន និងទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ហើយបំពេញភារកិច្ច តាមភារកិច្ចដែលប្រធានប្រគល់ជូន។

## មាត្រា ៦.-

អ.ជ.ម.ជ.អ. ត្រូវបើកសម័យប្រជុំពេញអង្គរបស់ខ្លួនយ៉ាងតិចពីរ (២) ដងក្នុងមួយឆ្នាំ ក្រោមអធិបតីភាព របស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមួយរូប ត្រូវដឹកនាំសម័យប្រជុំជំនួស។ តាមការចាំបាច់ប្រធាន អាចអញ្ជើញតំណាងសហគមន៍ អ្នកផ្តល់ជំនួយចូលរួមប្រជុំជាអ្នកសង្កេតការណ៍ ។

## មាត្រា ៧.-

ក្នុងការបំពេញបេសកកម្ម អ.ជ.ម.ជ.អ. មានសិទ្ធិចេញបទដ្ឋានផ្សេងៗ ក្នុងវិស័យប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានលក្ខណៈជាវិធានទូទៅក្តី ជាបុគ្គលក្តី ដែលអាជ្ញាធរគ្រប់ជាន់ថ្នាក់ ត្រូវយកទៅអនុវត្តឱ្យមានប្រសិទ្ធភាព។

## មាត្រា ៨.-

អ.ជ.ម.ជ.អ. មានសិទ្ធិប្រើប្រាស់ត្រាផ្ទាល់របស់ខ្លួន ។

## មាត្រា ៩.-

អ.ជ.ម.ជ.អ. មានរចនាសម្ព័ន្ធដូចតទៅ ៖

- ខុទ្ទកាល័យប្រធាន អ.ជ.ម.ជ.អ.
- អគ្គលេខាធិការដ្ឋាន
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ខេត្ត ក្រុង
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ស្រុក ខណ្ឌ

/

- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ឃុំ សង្កាត់ ។

អង្គការលេខរបស់ អ.ជ.ប.ជ.អ. ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូកទី ៣
## ខុទ្ទកាល័យប្រធាន អ.ជ.ប.ជ.អ.

**មាត្រា ១០.-**

ខុទ្ទកាល័យប្រធាន អ.ជ.ប.ជ.អ. ទទួលបន្ទុកបេសកកម្ម និងបំពេញភារកិច្ចទាំងឡាយ ដែលបានកំណត់តាមបញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូកទី ៤
## អគ្គលេខាធិការដ្ឋាន

**មាត្រា ១១.-**

អគ្គលេខាធិការដ្ឋាន ជាសេនាធិការឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ ។ អគ្គលេខាធិការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ហើយអគ្គលេខាធិការរង ត្រូវតែងតាំងដោយអនុក្រឹត្យ ។

អគ្គលេខាធិការដ្ឋានមានរចនាសម្ព័ន្ធដូចតទៅ ៖

- នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ
- នាយកដ្ឋាន ទាក់ទង និងចលនាប្រភពធនធាន
- នាយកដ្ឋាន ផែនការ ត្រួតពិនិត្យវាយតម្លៃ និងស្រាវជ្រាវ

អ.ជ.ប.ជ.អ. មានបុគ្គលិកជាមន្ត្រីរាជការ ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យាតាមការចាំបាច់ ។

**មាត្រា ១២.-**

អគ្គលេខាធិការមានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលបន្ទុកចាត់ចែង គ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាន
- រៀបចំកម្មវិធីការងារ របៀបវារៈ និងឯកសារផ្សេងៗសម្រាប់គ្រប់អង្គប្រជុំ
- រៀបចំធ្វើកំណត់ហេតុ សេចក្តីជូនដំណឹងពីកិច្ចប្រជុំ ដើម្បីដាក់ជូនប្រធានពិនិត្យ និងសម្រេច
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ

រៀបចំគម្រោងថវិកា និងចំណូល-ចំណាយ
រៀបចំប្រកាសព័ត៌មាន
សម្របសម្រួលការងារប្រចាំថ្ងៃ របស់អគ្គលេខាធិការដ្ឋាន
បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធាន អ.ជ.ប.ជ.អ. ប្រគល់ជូន។
លេខាធិការរងនីមួយៗ បំពេញកិច្ចការតាមភារកិច្ច ដែលអគ្គលេខាធិការប្រគល់ជូន។

កដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ៖
គ្រប់គ្រង និងចរាចរឯកសារផ្សេងៗ
ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល
បង្កើត ចែកចាយព្រឹត្តិបត្រព័ត៌មាន
រៀបចំរាល់កិច្ចប្រជុំ លិខិតបេសកកម្ម លិខិតអញ្ជើញ និង លិខិតនានា
គ្រប់គ្រងបុគ្គលិក មន្ត្រីរាជការ
គ្រប់គ្រងយានយន្ត និងយានដ្ឋានរបស់រដ្ឋ
រៀបចំឧបករណ៍សម្រាប់ការងារគណនេយ្យ និងហិរញ្ញវត្ថុ
គ្រប់គ្រងថវិកា ហិរញ្ញវត្ថុ ដែលទទួលបានពីថវិកាជាតិ ពីសហគមន៍អ្នកផ្តល់ជំនួយ និងពីប្រភពផ្សេងៗទៀត
សម្របសម្រួលជំពូកថវិកា លើកគម្រោងចំណូល-ចំណាយ
ផ្គត់ផ្គង់ និងគ្រប់គ្រងសម្ភារៈបរិក្ខារ
គ្រប់គ្រងលទ្ធកម្មសាធារណៈ
ធ្វើរបាយការណ៍កិច្ចប្រជុំនានា និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.ជ.ប.ជ.អ. ប្រគល់ជូន។

កដ្ឋាន បង្ការ ថែទាំ និងគាំទ្រ មានភារកិច្ច ដូចតទៅ ៖
ទាក់ទង និងសហការជាមួយភាគីពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ដើម្បីត្រួតពិនិត្យប្រសិទ្ធភាពនៃការគ្រប់គ្រង និងជំនាញបច្ចេកទេស ដែលទាក់ទងទៅនឹងសេវាកម្ម បង្ការ ថែទាំ និងគាំទ្រ
អភិវឌ្ឍ និងរក្សាសម្ភារៈឧបទេស សម្ភារៈហ្វឹកហ្វឺនទៅថ្នាក់ជាតិ និងអន្តរជាតិ
ធ្វើផែនការសម្រាប់ហ្វឹកហ្វឺន ដល់បណ្តាញដែលធ្វើការងារអេដស៍ជាពហុវិស័យ

- សម្របសម្រួល ជាមួយផ្នែកពាក់ព័ន្ធ ដើម្បីកំណត់ស្តង់ដា និងអភិវឌ្ឍសម្ភារៈសម្រាប់ហ្វឹកហ្វឺន
- សម្របសម្រួលការបង្កើនសមត្ថភាព ដល់អ្នកធ្វើការងារអេដស៍ទាំងអស់
- ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាព នៃសកម្មភាពហ្វឹកហ្វឺន
- ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និង ប្រចាំឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.ជ.ប.ជ.អ. ប្រគល់ជូន។

មាត្រា ១៥.-

នាយកដ្ឋាន ទាក់ទង និងចលនាប្រភពធនធាន មានភារកិច្ចដូចតទៅ ៖

- ទាក់ទងជាមួយដៃគូនានា ដើម្បីផ្សព្វផ្សាយព័ត៌មាន សមស្របសម្រាប់អប់រំឱ្យមានការ ផ្លាស់ប្តូរការប្រព្រឹត្តដែលប្រឈមមុខនឹងគ្រោះថ្នាក់ នៃការឆ្លងមេរោគអេដស៍
- ផ្សព្វផ្សាយ ទាក់ទាញឱ្យមានសេវាបង្ការ ថែទាំ និងគាំទ្រ ចំពោះអ្នករងគ្រោះដោយសារមេរោគអេដស៍/ ជំងឺអេដស៍
- ប្រមូលព័ត៌មានអំពីសកម្មភាពផ្សព្វផ្សាយ របស់ដៃគូទាំងឡាយ សម្រាប់បង្កើតគោលការណ៍ណែនាំ និងយុទ្ធសាស្ត្រ នៃសកម្មភាពផ្សព្វផ្សាយ និងចងក្រងឯកសារសម្រាប់បោះពុម្ពផ្សាយ
- អភិវឌ្ឍយុទ្ធសាស្ត្រផ្សព្វផ្សាយ និងទាក់ទងដើម្បីប្រយុទ្ធនឹងការរាលដាលមេរោគអេដស៍/ជំងឺអេដស៍
- រៀបចំសន្និសីទអំពីមេរោគអេដស៍/ជំងឺអេដស៍ សម្របសម្រួល និងចូលរួមរៀបចំព្រឹត្តិការណ៍ជាអាទិ៍ ក្នុងពិធីអុជភ្លើងទៀន រំលឹកវិញ្ញាណក្ខន្ធ ទិវាអេដស៍អន្តរជាតិ ពិធីបុណ្យអុំទូក អកអំបុក និងសំពះព្រះខែ
- បង្កើត ត្រួតពិនិត្យ រាល់សារអប់រំទាំងអស់ ទាក់ទងទៅនឹងមេរោគអេដស៍/ជំងឺអេដស៍ មុននឹងផ្សព្វផ្សាយ ដល់សាធារណជន
- សម្របសម្រួល និងស្វែងរកធនធានពីប្រភពផ្សេងៗ
- រៀបចំ និងសម្របសម្រួលជាមួយគ្រប់ផ្នែក និងបណ្តាញនៅតាមក្រសួង ស្ថាប័ន និងខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីកំណត់ឱ្យបានច្បាស់លាស់ និងតុល្យភាព នៃធនធានសម្រាប់ធ្វើសកម្មភាពស្របតាមផែនការយុទ្ធសាស្ត្រ និងដាក់បញ្ចូលទៅក្នុងផែនការមេ
- រៀបចំយន្តការការងារ ដើម្បីជៀសវាងការរាំងស្ទះលំហូរធនធាន និងត្រួតពិនិត្យការប្រើប្រាស់ធនធាន
- រៀបចំ និងសម្រួលឱ្យមានការប្រជុំ ជាមួយម្ចាស់ជំនួយលើតម្រូវការធនធាន ក្នុងការប្រយុទ្ធទប់ស្កាត់ការរីករាលដាល នៃមេរោគអេដស៍/ជំងឺអេដស៍
- ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.ជ.ប.ជ.អ. ប្រគល់ជូន។

>

មាត្រា ១៦.-

នាយកដ្ឋាន ផែនការ ត្រួតពិនិត្យវាយតម្លៃ និងស្រាវជ្រាវមានភារកិច្ចដូចតទៅ ៖

- រៀបចំ អភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ ជាលក្ខណពហុវិស័យ សម្រាប់ឆ្លើយតបទៅនឹងមេរោគអេដស៍/ជំងឺអេដស៍
- រៀបចំផែនការសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុងការធ្វើគោលនយោបាយ យុទ្ធសាស្ត្រផែនការសកម្មភាព សម្រាប់ឆ្លើយតបទៅនឹងច្បាប់ស្ដីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងឆ្លើយតបទៅនឹងមូលដ្ឋានដែលមានលក្ខណសម្បត្តិខុសៗគ្នា
- ត្រួតពិនិត្យមើលទំនោរអេពីដេមីសាស្ត្រនៃមេរោគអេដស៍/ជំងឺអេដស៍ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ
- ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.ជ.ប.ជ.អ. ប្រគល់ជូន ។

មាត្រា ១៧.-

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន តាមការចាំបាច់ ។

ប្រធាននាយកដ្ឋាននីមួយៗ ត្រូវតែងតាំងដោយអនុក្រឹត្យ ហើយអនុប្រធាននាយកដ្ឋាននីមួយៗ ត្រូវតែងតាំង ដោយប្រកាសរបស់ប្រធាន អ.ជ.ប.ជ.អ. ។

មាត្រា ១៨.-

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. មាន ក្រុមប្រឹក្សាបច្ចេកទេសមួយ ជាជំនួយការ មានសមាជិកជាមន្ត្រី ដែលចាត់តាំងដោយ ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ដែលជាសមាជិក អ.ជ.ប.ជ.អ. ។

មាត្រា ១៩.-

ក្រុមប្រឹក្សាបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. ត្រូវប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ ក្រោមអធិបតីភាពអគ្គលេខាធិការនៃ អ.ជ.ប.ជ.អ. ដើម្បី ៖

- រៀបចំគោលនយោបាយជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជូន អ.ជ.ប.ជ.អ.
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អនុវត្តគោលនយោបាយជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជូន អ.ជ.ប.ជ.អ.

- រៀបចំផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍
- ជួយណែនាំការអនុវត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីឆ្លើយតបដោយប្រសិទ្ធភាព ទៅនឹងតម្រូវការនៃស្ថានភាពមេរោគអេដស៍ ជំងឺអេដស៍
- អនុវត្តភារកិច្ចផ្សេងៗទៀតដែល **អ.ជ.ប.ជ.អ.** ប្រគល់ជូន ។

## ជំពូកទី ៥

## គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមក្រសួង ស្ថាប័ន

**មាត្រា ២០.-**

គ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ដឹកនាំដោយតំណាងតាមក្រសួង ស្ថាប័ន ដែលជាសមាជិកនៃ **អ.ជ.ប.ជ.អ.** ។

សមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមក្រសួង ស្ថាប័ន ដែលមកពីអង្គភាពនានា ត្រូវមានតួនាទី ចាប់ពីថ្នាក់នាយកដ្ឋានឡើងទៅ ។

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមក្រសួង ស្ថាប័នត្រូវបង្កើតដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមក្រសួង ស្ថាប័ន ត្រូវមានក្រុមការងារមួយជាជំនួយការ ។

**មាត្រា ២១.-**

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមក្រសួង ស្ថាប័ន មានភារកិច្ចដូចតទៅ ៖

- ធ្វើជាសេនាធិការ និងជាជំនួយការរបស់ **អ.ជ.ប.ជ.អ.**
- អនុវត្តនូវរាល់សេចក្តីសម្រេចរបស់ **អ.ជ.ប.ជ.អ.**
- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្ត តាមក្រសួង ស្ថាប័ន
- ផ្សព្វផ្សាយ អប់រំដល់មន្ត្រីក្រសួង ស្ថាប័ន និងសហគមន៍ពាក់ព័ន្ធ
- ចូលរួមរៀបចំគម្រោងថវិកា ជាមួយ **អ.ជ.ប.ជ.អ.**
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើជូន **អ.ជ.ប.ជ.អ.** ។

>

## ជំពូកទី ៦
## គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមខេត្ត ក្រុង

**មាត្រា ២២.-**

គ្រប់ខេត្ត ក្រុង ត្រូវបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ដឹកនាំដោយអភិបាល ឬអភិបាលរងខេត្ត ក្រុង មួយរូប ដែលជាសមាជិកនៃ **អ.ជ.ប.ជ.អ.** ។

សមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមខេត្ត ក្រុង រួមមាន នាយកសាខាកាកបាទក្រហមកម្ពុជា ប្រធានមន្ទីរជុំវិញខេត្ត ក្រុង និងអភិបាលគ្រប់ស្រុក ខណ្ឌ ។

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍តាមខេត្ត ក្រុង ត្រូវបង្កើតដោយដីកាខេត្ត ក្រុង ។

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍តាមខេត្ត ក្រុង ត្រូវមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលដឹកនាំ ដោយនាយខុទ្ទកាល័យសាលាខេត្ត ក្រុង ឬ ប្រធានមន្ទីរណាមួយជុំវិញខេត្ត ក្រុង ។

**មាត្រា ២៣.-**

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមខេត្ត ក្រុង មានភារកិច្ចដូចតទៅ ៖

- ធ្វើជាសេនាធិការ និងជាជំនួយការរបស់ **អ.ជ.ប.ជ.អ.**
- អនុវត្តនូវរាល់សេចក្តីសម្រេចរបស់ អ.ជ.ប.ជ.អ.
- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តតាមខេត្ត ក្រុង
- ផ្សព្វផ្សាយ អប់រំ ដល់មន្ត្រី ខេត្ត ក្រុង និងសហគមន៍ ពាក់ព័ន្ធ
- ចូលរួមរៀបចំគម្រោងថវិកា ជាមួយ អ.ជ.ប.ជ.អ.
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើជូន អ.ជ.ប.ជ.អ. ។

## ជំពូកទី ៧
## គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមស្រុក ខណ្ឌ

**មាត្រា ២៤.-**

គ្រប់ស្រុក ខណ្ឌ ត្រូវបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ដឹកនាំដោយអភិបាល ឬអភិបាលរងស្រុក ខណ្ឌ ។

សមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមស្រុក ខណ្ឌ រួមមាន គ្រប់ប្រធានការិយាល័យជុំវិញ ស្រុក ខណ្ឌ មេឃុំ និងចៅសង្កាត់ទាំងអស់ ។

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមស្រុក ខណ្ឌ ត្រូវបង្កើតដោយដីកាខេត្ត ក្រុង ។

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមស្រុក ខណ្ឌ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាជំនួយការ ដែលដឹកនាំដោយប្រធានមន្ទីរស្រុក ខណ្ឌ ។

/

មាត្រា ២៥.-

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមស្រុក ខណ្ឌ មានភារកិច្ច ដូចតទៅ ៖

- ធ្វើជាសេនាធិការ និងជាជំនួយការរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមខេត្ត ក្រុង
- អនុវត្តនូវរាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ក្រុង
- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្ត តាមស្រុក ខណ្ឌ
- ផ្សព្វផ្សាយ អប់រំ ដល់មន្ត្រី ស្រុក ខណ្ឌ និងសហគមន៍ពាក់ព័ន្ធ
- ចូលរួមរៀបចំគម្រោងថវិកា ជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមខេត្ត ក្រុង
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើជូនគណៈកម្មាធិការប្រយុទ្ធនឹង ជំងឺអេដស៍ តាមខេត្ត ក្រុង ។

## ជំពូកទី ៨

## គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមឃុំ សង្កាត់

មាត្រា ២៦.-

គ្រប់ឃុំ សង្កាត់ ត្រូវបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ដឹកនាំដោយមេឃុំ ឬចៅសង្កាត់ ។

សមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមឃុំ សង្កាត់ រួមមាន គ្រប់ប្រធានភូមិក្នុងឃុំ សង្កាត់ របស់ខ្លួន ។

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមឃុំ សង្កាត់ ត្រូវបង្កើតដោយដីកាស្រុក ខណ្ឌ ។

មាត្រា ២៧.-

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមឃុំ សង្កាត់ មានភារកិច្ច ដូចតទៅ ៖

- ជាសេនាធិការ និងជាជំនួយការរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមស្រុក ខណ្ឌ
- អនុវត្តនូវរាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមស្រុក ខណ្ឌ
- រៀបចំផែនការ គម្រោងថវិកា សកម្មភាពសម្រាប់អនុវត្ត តាមឃុំ សង្កាត់
- ផ្សព្វផ្សាយ អប់រំ ដល់មន្ត្រីឃុំ សង្កាត់ និងប្រជាពលរដ្ឋគ្រប់រូប
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើជូន គណៈកម្មាធិការប្រយុទ្ធនឹងជំងឺ-អេដស៍ ស្រុក ខណ្ឌ ។

## ជំពូកទី ៩
## អំពីការអនុវត្តគោលនយោបាយ

**មាត្រា ២៨.-**

សមាជិកនៃ **អ.ជ.ប.ជ.អ.** គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមក្រសួង ស្ថាប័ន គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមខេត្ត ក្រុង គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមស្រុក ខណ្ឌ និងតាមឃុំ សង្កាត់ទទួលខុសត្រូវចំពោះមុខ **អ.ជ.ប.ជ.អ.** ក្នុងការអនុវត្តគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រ និង ផែនការសកម្មភាព ដែលបានកំណត់ដោយ **អ.ជ.ប.ជ.អ.** ។

**មាត្រា ២៩.-**

ក្នុងការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ **អ.ជ.ប.ជ.អ.** ត្រូវដឹកនាំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមក្រសួង ស្ថាប័ន គណៈកម្មាធិការប្រយុទ្ធនឹង ជំងឺអេដស៍ តាម ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយផ្អែកទៅលើ ស្ថានភាពជាក់ស្តែង នៃមូលដ្ឋាននីមួយៗ។

## ជំពូកទី ១០
## ប្រភពធនធាន និងការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ៣០.-**

**អ.ជ.ប.ជ.អ.** មានប្រភពធនធាន ផ្គត់ផ្គង់ដោយថវិកាជាតិ និងដោយហិរញ្ញប្បទានសហប្រតិបត្តិការ ពីក្នុង និងក្រៅប្រទេស សម្រាប់បម្រើឱ្យវិស័យអេដស៍ ។

**មាត្រា ៣១.-**

ប្រធាន **អ.ជ.ប.ជ.អ.** ត្រូវរៀបចំថវិកាប្រចាំឆ្នាំ សម្រាប់ការប្រព្រឹត្តទៅរបស់ **អ.ជ.ប.ជ.អ.** គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ តាមក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា។

ថវិកា **អ.ជ.ប.ជ.អ.** គឺជាថវិកាអាទិភាព ហើយត្រូវបានរៀបចំដោយឡែក ជាថវិកាឧបសម្ព័ន្ធ ថវិការបស់ ក្រសួងសុខាភិបាល ។

ប្រធាន **អ.ជ.ប.ជ.អ.** ជាអាណាប័ក ។

**មាត្រា ៣២.-**

**អ.ជ.ប.ជ.អ.** មានកាតព្វកិច្ចប្រើប្រាស់ថវិកា ដែលទទួលបានឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដោយគោរពទៅតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងបទបញ្ជានានា ទាក់ទងនឹងការ គ្រប់គ្រង ហិរញ្ញវត្ថុ ជាធរមាន ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៣៣.-**

អនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០០ និង បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានសមាគមជាតិកាកបាទក្រហមកម្ពុជា អភិបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៤
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

អង្គការលេខរបស់ អ.ជ.ប.ជ.អ ដែលជាឧបសម្ព័ន្ធរបស់
អនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍




*កំណត់សម្គាល់ :*

- គ.ប.ជ.អ : គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍
- ន.រ.ហិ : នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ន.ប.ថ.គ : នាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ
- ន.ទ.ច.ធ : នាយកដ្ឋានទំនាក់ទំនង និង ចលនាប្រភពធនធាន
- ន.ផ.ត.វ.ស : នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១១០ អនក្រ. បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
